**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ....០៧៣..... អល/ ស.វ.ស

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈ (លើកទី២)**

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈ ។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលមានអាសយដ្ឋានឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី..២១..... ខែ..មិថុនា... ឆ្នាំ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០២៣ ៤៣០ ៥៥៩) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១០:០០ ព្រឹក.. ថ្ងៃទី..១១.. ខែ..កក្កដា... ឆ្នាំ២០១៦ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង១០:០០ ព្រឹក.... ថ្ងៃទី..១១.... ខែ..កក្កដា... ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការលើកពេលកែប្រែ និងលុបចោលការដេញថ្លៃ ក្នុងករណីមានភាពមិនប្រក្រតីណាមួយ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី..២០...... ខែ..មិថុនា ឆ្នាំ២០១៦
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

Sarlharak

**សាស្ត្រាចារ្យ.សាផុន_វឌ្ឍនៈ**

<u>ចម្លងជូន ៖</u>
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ